# សន្និសីទ ស្តីពី

# មីក្រូហិរញ្ញវត្ថុនៅកម្ពុជាអំឡុងពេលវិបត្តិហិរញ្ញវត្ថុ

# ផ្លូវខាងមុខសំរាប់ប្រទេសកម្ពុជា

# បញ្ហាច្បាប់ បទបញ្ញត្តិ និងការប្រឈមនានា

ដោយលោក ប្រេតតុន ស្ការ៉ូនី

ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០០៩

សណ្ឋាគារភ្នំពេញ

Sciaroni & Associates

# ការពិចារណាជាទូទៅ

- ការផ្លាស់ប្តូរឆាប់រហ័សនៃបរិស្ថានច្បាប់ និង បទបញ្ញត្តិនានា
- ជំនួយបច្ចេកទេសពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិបានជួយដល់ការរីកចំរើនបរិស្ថានហិរញ្ញវត្ថុវិជ្ជាជីវៈ
- ធនាគារជាតិកម្ពុជាជានិយ័តករដ៏មុឹងម៉ាត់ជាមួយនឹងការទទួលខុសត្រូវក្នុងការត្រួតពិនិត្យ
- រាល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុគួរតែមានអ្នកជំនាញផ្នែកច្បាប់ដើម្បីតាមដានរាល់ការផ្លាស់ប្តូរច្បាប់ និង បទបញ្ញត្តិនានា។

Sciaroni & Associates

# ការស្រាវជ្រាវ

- **បញ្ហានានាសម្រាប់អ្នកវិនិយោគដែលមានការចាប់អារម្មណ៍ក្នុងការវិនិយោគលើគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**
  - **ការខ្វះខាតនូវឯកសារសាធារណៈសំខាន់ៗ**
    - ក្រសួងពាណិជ្ជកម្ម
    - នាយកដ្ឋានពន្ធដារ
    - ការិយាល័យសុរិយោដី
  - **អាជ្ញាប័ណ្ណនានា :** អាជ្ញាប័ណ្ណគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ  អាជ្ញាប័ណ្ណធនាគារ
  - **ពុំមានភ្នាក់ងារផ្តល់ឥណទាន**
  - **ពុំមានឯកសារតុលាការដែលត្រូវបានរក្សាទុកជាប្រព័ន្ធនិងមានតម្លាភាព។**
  - **សារពតិមាន?**
  - **របាយការណ៏ប្រចាំឆ្នាំ**
    - ការតម្រូវឱ្យធ្វើសវនកម្មជាប្រចាំឆ្នាំរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ( ប្រការរបស់ធនាគារជាតិលេខ ៣៧ ។០៤-២០៤ ២០០៤ )
    - ប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ ៦៤៣( ឆ្នាំ២០០៧) ការធ្វើសវនកម្ម ប្រចាំឆ្នាំចំពោះក្រុមហ៊ុនទាំងឡាយដែលមានក៏រិតជាក់លាក់មួយ)

Sciaroni & Associates

# ការស្រាវជ្រាវ (ត)

## បន្ទុកលើចលនទ្រព្យ

- ពុំមានការចុះបញ្ជីជាផ្លូវការចំពោះរាល់បន្ទុកលើចលនវត្ថុនៅប្រទេសកម្ពុជា ។ រាល់ការដាក់បន្ទុកនានាជាកិច្ចព្រមព្រៀងឯកជនរវាងអ្នកទទួលការដាក់បន្ទុក អ្នកទទួលហ៊ីប៉ូតែក អ្នកទទួលការបញ្ចាំ និងបុគ្គលដែលយកទ្រព្យទៅដាក់បញ្ចាំ ដាក់ហ៊ីប៉ូតែក និងដាក់បន្ទុកនោះ ។ ការចុះបញ្ជីការដាក់បន្ទុកអាចធ្វើទៅបានតាមរយៈច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ( ឆ្នាំ ២០០៧) ក្នុងការតម្កល់លិខិតិជូនដំណឹងអំពីទ្រព្យដាក់ធានានៅការិយាល័យតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា ។ ទោះបីជាយ៉ាងណាក៏ដោយមិនមែនរាល់ការដាក់បន្ទុកទាំងអស់ត្រូវបានតម្កល់នៅការិយាល័យតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានានៅក្នុងករណីដែលការិយាល័យដំកល់ការជូនដំណឹងរបស់ប្រតិបត្តិការដែលមានកិច្ចធានាពុំបានធ្វើការវាយតំលៃអំពីសុពលភាពនៃការដាក់បន្ទុកដែលបានតម្កល់ ។ ដូច្នេះការស្រាវជ្រាវនៅលើគេហទំព័រនៃការិយាល័យតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិ ការដែលមានកិច្ចធានាគ្រាន់តែផ្តល់នូវការមើលឃើញពុំគ្រប់គ្រាន់អំពីបន្ទុករបស់ក្រុមហ៊ុនឡើយ ។
- **សំគាល់**
  - អ្នកវិនិយោគបរទេសតែងតែពឹងផ្អែកលើគណនីក្នុងស្រុករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាជាងការពិនិត្យដោយឯករាជ្យចំពោះការចុះបញ្ជីជា សាធារណៈ
  - ជាមួយគ្នានេះដែរគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុកអាចមានការលំបាកក្នុងការវាយតំលៃថាតើអ្នកផ្តល់កម្ចីជាសក្តានុពលទាំងនោះបានដាក់បន្ទុកចំពោះទ្រព្យរបស់ខ្លួនឬមានការពាក់ព័ន្ធនឹងបណ្តឹងឬអត់ ។

Sciaroni & Associates

# សុក្រិត្យកម្មនៃទ្រព្យធានាដែលមានកំរិត (ចលនវត្ថុ)

- អ្នកវិនិយោគបរទេសដែលផ្តល់ហិរញ្ញប្បទានដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងស្រុកនឹងស្វែងរកការការពារចំពោះការវិនិយោគដោយទ្រព្យធានា ។ ចំពោះករណីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងស្រុក ភាគច្រើននៃទ្រព្យដែលយកមកដាក់ធានា គឺជាចលនទ្រព្យ ដោយសារតែយើងមើលឃើញថាមិនសូវមានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលកាន់កាប់ដី ។ ដូចដែលបានរៀបរាប់ពីខាងលើ ផលប្រយោជន៍លើចលនទ្រព្យត្រូវបានតម្កល់ទៅការិយាល័យតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា ប៉ុន្តែច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានាមិនបានចែងអំពីប្រព័ន្ធចុះបញ្ជី (ដោយមានការិយាល័យតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិ ការដែលមានកិច្ចធានាជាអ្នកវាយតំលៃទៅលើសុពលភាពនៃទ្រព្យធានាដែលបានតម្កល់) ។ ជាក់ស្តែង នរណាម្នាក់ដែលបានបង់ទឹកប្រាក់ចំនួន ពីរ ឬ បី ពាន់រៀល អាចតម្កល់ការជូនដំណឹងអំពីប្រយោជន៍ចំពោះជនទីបីបាន ។ អវត្តមាននៃឯករាជ្យអព្យាក្រឹត្យចំពោះដំណើរការនៃការវាយតំលៃទៅលើសុក្រិតកម្មនៃទ្រព្យធានាដោយការិយាល័យតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិ ការដែលមានកិច្ចធានាមិនអាចធានាការពារផលប្រយោជន៍របស់អ្នកវិនិយោគបានទេ ។ ការិយាល័យនេះអាចត្រឹមតែផ្តល់អោយនូវសេចក្តីសន្និដ្ឋានអំពីអាទិភាពតែប៉ុណ្ណោះ ។
- **សំគាល់ :** នៅក្នុងការអនុវត្ត ទ្រព្យធានាដែលអ្នកវិយោគអាចទទួលបាន គឺការដាក់បន្ទុកទៅលើភាគហ៊ុនរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ឬកិច្ចធានាដោយបុគ្គលដែលធ្វើឡើងដោយអភិបាល ឬម្ចាស់ភាគហ៊ុន ។

Sciaroni & Associates

# សុក្រិត្យកម្មនៃទ្រព្យធានាដែលមានភិរតេ
# (អចលនវត្ថុ)

- តាមច្បាប់ មានតែការដាក់ហ៊ីប៉ូតែកអចនលទ្រព្យដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ប៉ុណ្ណោះដែលអាចចុះបញ្ជីនៅរដ្ឋបាលសុរិយោដី ។ ទោះបីជាយ៉ាងណាក៏ដោយនៅក្នុងការអនុវត្ត ម្ចាស់ដីភាគច្រើននៅមិនទាន់មានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ជាពិសេសនៅតំបន់ជនបទដែលជាគោលដៅរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ។
- លើសពីនេះទៅទៀត ប្រព័ន្ធចុះបញ្ជីប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចនលវត្ថុ ឬ វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ មានភាពខុសប្លែកគ្នាពីការិយាល័យសុរិយោដីមួយ ទៅការិយាល័យមួយទៀត ។ ការដែលពុំមានបទដ្ឋានរួម និងតម្លាភាព នៅក្នុងនីតិវិធីចុះបញ្ជី បង្ករអោយមានការលំបាកដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្នុងការប៉ានស្មានទៅ លើតំលៃ និងពេលវេលានៃដំណើរការចុះបញ្ជីនោះ.

Sciaroni & Associates

# ភាពមិនច្បាស់លាស់នៅក្នុងការអនុវត្តចំពោះទ្រព្យធានា

- **បណ្តឹងវិវាទ : តុលាការទាំងបីថ្នាក់មាន**
  - ធនាធានមានកំរិត
  - សំណុំរឿងមានចំនួនច្រើន
  - មេធាវីមានចំនួនកំណត់
- **យន្តការដោះស្រាយវិវាទជាឯកទេស**
  - វិវាទដីធ្លី : គណៈកម្មការសុរិយោដី និងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
  - វិវាទការងារជាសមូហភាព : ក្រុមប្រឹក្សាអាជ្ញាកណ្តាល ( សូមមើលគេហទំព័រ www.arbitrationcouncil.org )
  - វិវាទការងារទូទៅ : តុលាការការងារមិនទាន់បង្កើតនៅឡើយ
  - វិវាទពាណិជ្ជកម្ម : ច្បាប់ស្តីតុលាការពាណិជ្ជកម្មកំពុងត្រូវបានពង្រាង
- **ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ**
  - មានការអនុវត្តជាប្រពៃណីនូវការផ្សះផ្សារនូវវិវាទ
  - ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ( ចែងអំពីមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម)
  - កិច្ចសន្យាពាណិជ្ជកម្មជាទូទៅចែងអំពីមជ្ឈត្តកម្មនៅក្រៅប្រទេសកម្ពុជា ( ឧទា. ICC មជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិសឹង្ហបុរី)
  - ប្រទេសកម្ពុជាជាភាគីនៃអនុសញ្ញាក្រុងញ៉ូវយ៉កស្តីពីការទទួលស្គាល់និងការប្រតិបត្តិសេចក្តីសម្រេច របស់មជ្ឈត្តករបរទេសហើយអនុសញ្ញានេះត្រូវបានអនុម័តជាច្បាប់របស់ប្រទេសក្នុងការប្រតិបត្តិនូវលក្ខខណ្ឌនៃអនុសញ្ញា នេះ ( រាប់បញ្ចូលទាំងក្រមនីតិវិធីរដ្ឋប្បវេណី)

Sciaroni & Associates

# បញ្ហានានាចំពោះការអនុវត្តសេចក្ដីសំរេចរបស់មជ្ឈត្តករបរទេស

- អ្នកវិនិយោគបរទេសភាគច្រើនចូលចិត្តដាក់ការវិនិយោគរបស់ពួកគេអោយស្ថិតនៅក្រោមច្បាប់បរទេស និងសមត្ថកិច្ចតុលាការបរទេស ឬមជ្ឈត្តកម្មបរទេស ។ ប៉ុន្តែ នេះគឺជាហានិភ័យមួយដែលតុលាការកម្ពុជានឹងមិនអនុវត្តសាលក្រមតុលាការឬសេចក្ដីសំរេចរបស់មជ្ឈករបរទេសដោយស្វ័យប្រវត្តិ ។
  - ការអនុវត្តសាលក្រមបរទេសៈ ក្រមនីតិវិធីរដ្ឋប្បវេណី ដែលចូលជាធរមាននៅខែកក្កដា ឆ្នាំ ២០០៧ បានទទួលស្គាល់សុពលភាព របស់សាលក្រមតុលាការបរទេស ដោយមានលក្ខខ័ណ្ឌមួយចំនួន និងជាពិសេសគឺការធានាទៅវិញទៅមករវាងប្រទេសកម្ពុជា និងប្រទេស បរទេសដែលតុលាការនោះស្ថិតនៅ ។ តាមការយល់ដឹងរបស់យើងខ្ញុំ រហូតមកដល់សព្វថ្ងៃនេះការអនុវត្តសាលក្រមរបស់តុលាការបរទេសមិនទាន់ត្រូវបានយកមកអនុវត្តនៅកម្ពុជាឡើយទេ ហើយតាមការយល់ដឹងរបស់យើងខ្ញុំបច្ចុប្បន្ននេះ ក៏គ្មានកិច្ចព្រមព្រៀង ស្ដីពីការអនុវត្តសាលក្រមរបស់តុលាការទៅវិញទៅមករវាងកម្ពុជា និង ប្រទេសដទៃទៀតដែលចូលជាធរមាននោះដែរ វាអាចថាតុលាការកម្ពុជាអាចនឹងធ្វើការពិចារណាឡើងវិញទៅលើអង្គសេចក្ដីមុននឹងសំរេចថាតើគួរអនុវត្ត ឬ មិនអនុវត្តសាលក្រមរបស់តុលាការបរទេសនោះ ។ ដូច្នេះនៅ ពេលមានជម្លោះរវាងគូភាគីទៅលើកិច្ចព្រមព្រៀងវិនិយោគ សាលក្រមរបស់តុលាការបរទេស ដោយផ្អែកលើច្បាប់បរទេសនឹងមិនត្រូវបានអនុវត្តជាស្វ័យប្រវត្តិនៅក្នុងប្រទេសកម្ពុជាឡើយ ។

Sciaroni & Associates

# បញ្ហានានាចំពោះការអនុវត្តសេចក្តីសំរេចរបស់មជ្ឈត្តករបរទេស (បន្ត)

- **ការអនុវត្តសេចក្តីសម្រេចមជ្ឈត្តករបរទេសៈ** ដោយហេតុថាប្រទេសកម្ពុជាបានផ្តល់សច្ចាប័នចំពោះអនុសញ្ញា ក្រុងញ៉ូវយកស្តីពីការទទួលស្គាល់និងការប្រតិបត្តិសេចក្តីសម្រេច របស់មជ្ឈត្តករបរទេសកាលពីខែឧសភាឆ្នាំ ២០០១ និងអនុម័តច្បាប់ក្នុងស្រុកដែលចាំបាច់ សេចក្តីសម្រេចរបស់មជ្ឈត្តករបរទេសគួរតែចងជាកាតព្វកិច្ចនិង អាចប្រតិបត្តិបានចំពោះភាគីទាំងឡាយនៅកម្ពុជា ។ ទោះបីជាយ៉ាងនេះក្តី គួរកត់សំគាល់ថាការអនុវត្តច្បាប់ នាពេលបច្ចុប្បន្នបានស្នើជាយោបល់ថាជានិច្ចជាកាលតុលាការកម្ពុជាអាចមិនមានឆន្ទៈឬលទ្ធភាពដើម្បីទទួល ស្គាល់ឬអនុវត្តសេចក្តីសម្រេចរបស់មជ្ឈករបរទេសដោយពុំបានពិនិត្យឡើងវិញនូវអង្គសេចក្តីនៃករណីនោះឡើយ ។

# ភាពពុំច្បាស់លាស់នៃច្បាប់ផ្សេងទៀត

- តាមច្បាប់កិច្ចសន្យាកម្ពុជា អត្រាការប្រាក់ជាអតិបរមាចំពោះកម្ចីនៅកម្ពុជាគឺចំនួន៥ភាគរយក្នុងមួយឆ្នាំ *"លើកលែងតែមានបទបញ្ញត្តិថែងផ្សេងពីនេះ"* (មាត្រា ៥៩) ។ ទោះបីយ៉ាងណាក៏ដោយ បញ្ញត្តិជាបន្តបន្ទាប់ ដែលចេញដោយធនាគារជាតិកម្ពុជាត្រូវបានបកស្រាយដោយរដ្ឋាភិបាលថា អនុញ្ញាតិឱ្យធនាគារនិងគ្រឹះស្ថាន ហិរញ្ញវត្ថុនានាធ្វើការកម្រិតអត្រាការប្រាក់ចំពោះប្រាក់បញ្ញើនិងកម្ចីក្នុងអត្រាតាមការចរចាររវាងភាគី ទាំងឡាយនៅក្នុងការដាក់ប្រាក់បញ្ញើរនិងកម្ចី ។ តាមច្បាប់ បញ្ញត្តិដែលចេញដោយធនាគារ ជាតិនៃកម្ពុជាមានឋានានុក្រមត្រឹមតែជាបញ្ញត្តិដែលចេញដោយក្រសួងប៉ុណ្ណោះ ហើយពុំមានឋានានុក្រមខ្ពស់ ជាងច្បាប់ស្តីពីកិច្ចសន្យាឡើយ ។ ជាការអនុវត្តជាក់ស្តែង បញ្ញត្តិត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលថាបាន លុបចោលនូវប្រការដែលថែងអំពីអត្រាការប្រាក់ចំនួន៥ភាគរយនៅក្នុងច្បាប់កិច្ចសន្យាទាក់ទងនឹងធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុ ។ វានៅតែជាភាពពុំច្បាស់លាស់នៃច្បាប់សំរាប់អ្នកវិនិយោគបរទេសលើវិស័យ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុក ។

Sciaroni & Associates

**សូមអរគុណ**

***ចំពោះការយកចិត្តទុកដាក់របស់អស់លោក លោកស្រី !***

**ចំពោះពត៌មានបន្ថែម សូមទាក់ទងអ៊ីម៉ែល**

**info@sa-cambodia.com**

Sciaroni & Associates